**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**
លេខ ៣៤៤ សជណ.ទសច

**គណៈកម្មាធិការជាតិ**
**វាយតម្លៃទីក្រុងស្អាត**

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែសីហា ឆ្នាំ ២០១៦

# សេចក្តីជូនដំណឹង
# ស្តីពី
# រង្វាន់សម្រាប់ "ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការប្រើប្រាស់ផលិតផលខ្មែរ" ក្នុងចលនាប្រឡងប្រណាំង "រង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍" ឆ្នាំ២០១៦

ដើម្បីធានាឲ្យមានការបែងចែកផ្លែផ្កានៃកំណើនពីវិស័យទេសចរណ៍ប្រកបដោយសមធម៌ ពិសេសការលើកស្ទួយ **"វិស័យទេសចរណ៍ ជាការនាំចេញនៅនឹងកន្លែង"** ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រសួងទេសចរណ៍/គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតបានដាក់ចេញនូវយុទ្ធនាការ **"រួមគ្នាប្រើប្រាស់ផលិតផលខ្មែរក្នុងឧស្សាហកម្មទេសចរណ៍"** ដែលនឹងជួយដល់ផលិតករក្នុងស្រុក ដែលជាប្រជាកសិករ ម្ចាស់សិប្បកម្ម ម្ចាស់សហគ្រាសធុនតូច និងមធ្យម ផលិតវត្ថុអនុស្សាវរីយ៍ និងអ្នកពាក់ព័ន្ធដទៃទៀតក្នុងការទទួលបានឱកាសបន្ថែមក្នុងការផ្សព្វផ្សាយ និងស្វែងរកទីផ្សារសម្រាប់ផលិតផលខ្មែរនៅក្នុងឧស្សាហកម្មទេសចរណ៍។

ក្រសួងទេសចរណ៍/គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត សូមជម្រាបជូនដល់មន្ទីរទេសចរណ៍រាជធានី-ខេត្ត ប្រតិបត្តិករទេសចរណ៍នៅតាមរមណីយដ្ឋាន សណ្ឋាគារ ភោជនីយដ្ឋាន ទីភ្នាក់ងារទេសចរណ៍ កីឡាទេសចរណ៍ សហគមន៍ទេសចរណ៍ សាលាទេសចរណ៍ ផ្សារទំនើប ក្រុមហ៊ុន សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យទេសចរណ៍ និងធុរកិច្ចពាក់ព័ន្ធទាំងអស់ ឲ្យបានជ្រាបថា ក្រសួងទេសចរណ៍បានរៀបចំបង្កើតប្រភេទរង្វាន់ថ្មីមួយទៀតគឺ ***រង្វាន់សម្រាប់ "ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការប្រើប្រាស់ផលិតផលខ្មែរ"*** (Khmer Product Usage Award) បន្ថែមលើប្រភេទរង្វាន់ទាំង០៦ ក្នុងចលនាប្រឡងប្រណាំង **"រង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍"**។ ជ័យលាភីនៃរង្វាន់ធុរកិច្ចដែលមានស្នាដៃឆ្នើមក្នុងការប្រើប្រាស់ផលិតផលខ្មែរ នឹងត្រូវប្រកាស និងប្រគល់ជ័យលាភី នាឱកាស**វេទិកាជាតិធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ លើកទី១** នាចុងឆ្នាំ២០១៦ ខាងមុខនេះ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកក្រសួងទេសចរណ៍ ឬអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតរៀងរាល់ម៉ោងធ្វើការ តាមរយៈលេខទូរស័ព្ទ ០៩៦ ៣៥ ៧៨៦ ៣២ ឬអ៊ីម៉ែល cambodiaecobusiness@yahoo.com។

ទទួលបានសេចក្តីជូនដំណឹងនេះ សូម លោក-លោកស្រី ដែលជាប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្ត ប្រតិបត្តិករ និងធុរជនក្នុងវិស័យទេសចរណ៍នៅទូទាំងព្រះរាជាណាចក្រកម្ពុជា មេត្តាជ្រាបជាព័ត៌មាន សហការផ្សព្វផ្សាយ និងចូលរួមក្នុងចលនាប្រឡងប្រណាំងខាងលើនេះឱ្យបានផុសផុល៕

**រដ្ឋមន្ត្រី**

**ថោង ខុន**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- សហប្រធានក្រុមការងារផ្នែកឯកជនក្នុងវិស័យទេសចរណ៍
- សហព័ន្ធទេសចរណ៍កម្ពុជា
- សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា
- សមាគមសណ្ឋាគារកម្ពុជា
- សមាគមភោជនីយដ្ឋានកម្ពុជា

"ដើម្បីជ្រាប និងសហការផ្សព្វផ្សាយ"

- *ឯកសារ-កាលប្បវត្តិ*